# ការពិតទាំង ១០ ដែលអ្នកគួរដឹង ពីកម្មវិធីហ្វូតស្ដែម

**ការពិត ៖** កម្មវិធីជំនួយហ្វូតស្ដែមមិនមែនជាកម្មវិធីវែលហ្វែរឡើយ ។ វាគឺជាកម្មវិធីឧបត្ថម្ភម្ហូបអាហារ អោយបានគ្រប់គ្រាន់ ដើម្បីជួយដល់បុគ្គល និងគ្រួសារទាំងឡាយ ដែលមានប្រាក់ចំណូលតិចតួច អោយទិញ និងបរិភោគចំណីអាហារអោយបានគ្រប់គ្រាន់ ។

**ការពិត ៖** កម្មវិធីហ្វូតស្ដែម គឺជាកម្មវិធីមួយដែលផ្ដល់សិទ្ធិឱ្យប្រជាពលរដ្ឋទទួលជំនួយ ។ ឬអាចនិយាយម្យ៉ាងទៀតថា មនុស្សគ្រប់រូបដែលដាក់ពាក្យសុំ និងដែលត្រូវបានគេកំណត់ថាអាចទទួលជំនួយហ្វូតស្ដែមបាន ។

**ការពិត ៖** ហ្វូតស្ដែមគឺផ្ដល់ជូនបុគ្គល ហើយនិងគ្រួសារទាំងឡាយ ដែលមានសិទ្ធិអាចទទួលយកជំនួយបាន ដោយរាប់បញ្ចូលទាំងមនុស្សចាស់, ជនពិការ, អ្នកធ្វើការតាមផ្ទះ, ជនអន្តោប្រវេសន៍ស្របច្បាប់មួយចំនួន និងកូនរបស់គេដែលបានកើតនៅក្នុងសហរដ្ឋអាមេរិក ។

**ការពិត ៖** បុគ្គលទាំងអស់ដែលអាចមានផ្ទះស្រាប់ហើយក៏ដោយ ក៏នៅតែទទួលហ្វូតស្ដែមបានដែរ ។ ផ្ទះ និង ដីឡូត៍មិនត្រូវបានគេរាប់បញ្ចូលថាជាធនធានក្នុងកម្មវិធីហ្វូតស្ដែមទេ ។ កម្មវិធីហ្វូតស្ដែមមិនតម្រូវ អោយមនុស្សបោះបង់ផ្ទះរបស់គេចោលឡើយ ។

**ការពិត ៖** ក្នុងឆ្នាំ ២០០០ មនុស្សចាស់ដែលរស់នៅតែម្នាក់ឯងបានទទួលប្រាក់បានជាមធ្យមចំនួន ៤៣ ដុល្លា ក្នុងមួយខែ និងមនុស្សចាស់ដែលមិនរស់នៅតែឯងទទួលបានប្រាក់ជាមធ្យម ១១៨ ដុល្លា ក្នុងមួយខែ ។

**ការពិត ៖** បើសិនជាមនុស្សចាស់ ឬ ជនពិការមិនអាចមាលលទ្ធភាពទៅការិយាល័យហ្វូតស្ដែមបាន គេអាច ស្នើសុំឱ្យមានការសម្ភាសន៍តាមទូរស័ព្ទ ។ បុគ្គលនោះក៏អាចសុំអោយសាច់ញាតិ, អ្នកចាស់ទុំក្នុងភូមិ, អ្នកជិតខាង ។ល។ ដើម្បីមកចូលរួមសម្ភាសន៍ ជាតំណាងអ្នកមានសិទ្ធិម្នាក់ផងដែរ ។ បេក្ខជន ឬអ្នកទទួលប្រាក់ចំណូលសន្តិសុខបន្ថែម (Supplemental Security Income-SSI) ក៏អាចដាក់ពាក្យសុំជំនួយហ្វូតស្ដែមនៅការិយាល័យ សន្តិសុខសង្គមបានដែរ ។

**ការពិត ៖** ចំណាយសម្រាប់សុខភាពដែលលើសពី ៣៥ ដុល្លា ក្នុងមួយខែ អាចត្រូវបានគេកាត់ពីប្រាក់ចំណូលក្នុងផ្ទះសរុប លើកលែងតែក្រុមហ៊ុនធានារ៉ាប់រង ឬនរណាម្នាក់ដែលមិនមែនជាសមាជិកក្នុងផ្ទះបង់ប្រាក់ឱ្យគេ ។ ចំនួនដែលលើសពី ៣៥ ដុល្លា អាចត្រូវបានគេកាត់បន្ថយ ។

**ការពិត ៖** ធនធានកំណត់សម្រាប់មនុស្សចាស់ដែលជាមេគ្រួសារ ឬគ្រួសារដែលមានសមាជិកជាមនុស្សចាស់ម្នាក់ គឺមានចំនួនរហូតដល់ ៣.000 ដុល្លា ។ ធនធានកំណត់សម្រាប់ក្រុមគ្រួសារដទៃទៀត គឺមានចំនួនរហូតដល់ ២.000 ដុល្លា ។

**ការពិត ៖** ក្រុមគ្រួសារទាំងអស់អាចទទួលជំនួយហ្វូតស្ដែម ហើយនៅតែទទួលបានជំនួយរបបអាហារផ្គត់ផ្គង់ចំណើអាហារ (Meals-on-Wheels) កម្មវិធីអាហារបំប៉នពិសេសមួយសម្រាប់ស្ត្រី ទារក និងកូនក្មេង (Special Supplemental Nutrition Program for Women, Infants and Children - WIC) និងជំនួយម្ហូបអាហារសំរាប់កុមារ ដូចជាកម្មវិធីអាហារថ្ងៃត្រង់តាមសាលារៀន (School Lunch Program) ជាដើម ។

**ការពិត ៖** ការទទួលជំនួយពីកម្មវិធីហ្វូតស្ដែម នឹងមិនធ្វើអោយក្រុមគ្រួសារដែលមានសមាជិកជាជនអន្តោប្រវេសន៍ស្របច្បាប់ ទទួលនូវការចោទប្រកាន់ជាសាធារណៈឡើយ ។

***ហ្វូតស្ដែមធ្វើឱ្យអាមេរិកកាន់តែខ្លាំងឡើង ។***

*ក្រសួងកសិកម្មនៃសហរដ្ឋអាមេរិក (United States Department of Agriculture - USDA) គឺជាអ្នកផ្ដល់ និង កន្លែងឱ្យឱកាសស្មើភាពគ្នា ។*